ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៦៦ អយក.ឋ.៦

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ** : សំណើសុំកែសម្រួលប្រកាសអន្តរក្រសួងលេខ៥០៥ សហវ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០១ ស្តីពីគោលការណ៍សម្រាប់ការប្រឡងមធ្យមសិក្សាចំណេះទូទៅ ប្រឡងឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេស និងវិជ្ជាជីវៈ ប្រឡងគ្រូបង្រៀន និងប្រឡងអាហារូបករណ៍។

**យោង** : លិខិតលេខ៦៨៩២ សហវ.ហក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា៖ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តន៍ប្រកាសអន្តរក្រសួងលេខ៥០៥ សហវ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០១ ស្តីពីគោលការណ៍សម្រាប់ការប្រឡងមធ្យមសិក្សាចំណេះទូទៅ ប្រឡងឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេស និងវិជ្ជាជីវៈ ប្រឡងគ្រូបង្រៀន និងប្រឡងអាហារូបករណ៍ រហូតមកដល់បច្ចុប្បន្នមានរយៈពេល១៥ឆ្នាំហើយ។ ដោយការប្រឡងសព្វថ្ងៃមានការប្រែប្រួលច្រើនពាក់ព័ន្ធនឹងនិយាមប្រើប្រាស់គណៈកម្មការ រយៈពេលបំពេញការងារ ជាពិសេសប្រាក់ឧបត្ថម្ភដល់គណៈកម្មការមេប្រយោគនិងគណៈកម្មកាផ្សេងៗ មិនឆ្លើយតបទៅកំណើនសេដ្ឋកិច្ចនិងកម្មវិធីកែទម្រង់ប្រព័ន្ធអប់រំនៅកម្ពុជា។ ដូចនេះក្រសួងស្នើសុំកែសម្រួលប្រកាសអន្តរក្រសួងលេខ៥០៥ សហវ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០១ ដើម្បីដាក់ឱ្យអនុវត្តន៍គ្រប់ការប្រឡងក្នុងឆ្នាំ២០១៦។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាអនុញ្ញាតឱ្យកែសម្រួលនូវប្រកាសអន្តរក្រសួងថ្មី ដែលបានរៀបចំ ដោយក្រសួងអប់រំ យុវជន និងកីឡា តាមការគួរ។

**<u>សូមជូនភ្ជាប់មកជាមួយនូវៈ</u>**

សេចក្តីព្រាងប្រកាសអន្តរក្រសួងថ្មី ស្តីពីគោលការណ៍សម្រាប់ការប្រឡងមធ្យមសិក្សាចំណេះទូទៅ និងបំពេញវិជ្ជា ប្រឡងឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេស និងវិជ្ជាជីវៈ ប្រឡងគ្រូបង្រៀន និងប្រឡងអាហារូបករណ៍នៅក្រសួងអប់រំ យុវជន និងកីឡា ។

សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

-កាលប្បវត្តិ

-ឯកសារ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..................សហវ.....

# ប្រកាសអន្តរក្រសួង
## ស្តីពី
## គោលការណ៍សម្រាប់ចំណាយក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាចំណេះទូទៅនិងបំពេញវិជ្ជា ប្រឡងឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេសនិងវិជ្ជាជីវៈ ប្រឡងគ្រូបង្រៀន និងប្រឡងអាហារូបករណ៍

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ　　　　រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664　Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសអន្តរក្រសួងនេះមានគោលបំណងលើកកម្ពស់គុណភាពអប់រំនៅគ្រប់ភូមិសិក្សា។

**ប្រការ២ .-**

ប្រកាសអន្តរក្រសួងនេះមានគោលដៅកំណត់ចំនួនគណៈកម្មការ និយាមប្រើប្រាស់និងរយៈពេលបំពេញការងារ និងប្រាក់ឧបត្ថម្ភរបស់គណៈមេប្រយោគនិងគណៈកម្មការផ្សេងៗក្នុងនោះៈ

- ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិចំណេះទូទៅនិងបំពេញវិជ្ជា
- ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅនិងបំពេញវិជ្ជា
- ការប្រឡងជ្រើសរើសនិងប្រឡងបញ្ចប់ការបណ្តុះបណ្តាល គ្រូបង្រៀនកម្រិតបឋម (មត្តេយ្យសិក្សា និងបឋមសិក្សា) គ្រូបង្រៀនកម្រិតមូលដ្ឋាន គ្រូបង្រៀនកម្រិតឧត្តម(មធ្យមសិក្សាទុតិយភូមិ/ឧត្តមសិក្សា) អធិការអប់រំ
- ការប្រឡងជ្រើសរើស ការប្រឡងបញ្ចប់ការសិក្សា ការជ្រើសរើសនិស្សិតអាហារូបករណ៍និងការការពារសារណាឬគម្រោងបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- ការប្រឡងជ្រើសរើសអាហារូបករណ៍ទៅសិក្សានៅបរទេស។

**ប្រការ៣ .-**

ប្រកាសអន្តរក្រសួងនេះមានវិសាលភាពអនុវត្តចំពោះថ្នាក់ដឹកនាំ បុគ្គលិកអប់រំ និងមន្ត្រីស្ថាប័នពាក់ព័ន្ធដែលត្រូវបានចាត់តាំងជាសមាសភាពនៃគណៈកម្មការនានាក្នុងការប្រឡងនិងការជ្រើសរើស។

## ជំពូកទី២

## ការរៀបចំគណៈមេប្រយោគនិងគណៈកម្មការផ្សេងៗ

**ប្រការ៤ .-**

សម័យប្រឡងនិងការជ្រើសរើសនីមួយៗ ត្រូវបានចែកជាបីដំណាក់កាលគឺៈ

- ដំណាក់កាលរៀបចំការប្រឡងនិងការជ្រើសរើស
- ដំណាក់កាលសំណេរ ការជ្រើសរើស និងការប្រតិបត្តិ
- ដំណាក់កាលកំណែ ស្រង់បូក និងប្រកាសលទ្ធផល។ ដោយឡែកការប្រឡងសញ្ញាបត្រ

មធ្យមសិក្សាទុតិយភូមិត្រូវបន្ថែមដំណាក់កាលទី៤គឺ៖ ដំណាក់កាលស្រង់បូកពិន្ទុដោយកុំព្យូទ័រ និងប្រកាសលទ្ធផល។ ចំពោះគ្រឹះស្ថានឧត្តមសិក្សាការការពារសារណាឬគម្រោងប្រឡងបញ្ចប់ការសិក្សាត្រូវបានគិតជាដំណាក់កាលប្រឡងដោយឡែក។

**ប្រការ៥ .-**

ត្រូវបានបង្កើតគណៈមេប្រយោគនិងគណៈកម្មការផ្សេងៗ ដើម្បីរៀបចំនិងគ្រប់គ្រងដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិនិងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដូចខាងក្រោម៖

**១. ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិត្រូវមាន៖**

- ប្រធាន និងអនុប្រធានមណ្ឌល
- គណៈកម្មការកំណែ
- គណៈកម្មការគណនេយ្យនិងសម្ភាររាជធានី ខេត្ត
- គណៈកម្មការប្រឡងផ្សេងៗ
- គណៈកម្មការផ្តល់វិញ្ញាបនបត្របណ្តោះអាសន្ន

**២ . ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិត្រូវមាន៖**

- គណៈកម្មការរៀបចំការប្រឡងថ្នាក់កណ្តាល
- គណៈកម្មការរៀបចំការប្រឡងថ្នាក់រាជធានី ខេត្ត
- គណៈកម្មការគ្រប់គ្រងតាក់តែង និងវេចខ្ចប់ប្រធានវិញ្ញាសា
- គណៈមេប្រយោគទូទាំងប្រទេស
- គណៈកម្មការអប្បមាទទូទាំងប្រទេស
- ប្រធាន និងអនុប្រធានមណ្ឌលសំណេរ
- គណៈកម្មការត្រួតពិនិត្យតាមអគារ
- គណៈកម្មការកណ្តាលសំណេរ
- គណៈកម្មការអនុរក្ស
- គណៈមេប្រយោគទូទាំងប្រទេសកំណែ
- ប្រធានមណ្ឌលកំណែ
- អនុប្រធានមណ្ឌលកំណែ
- គណៈកម្មការកណ្តាលកំណែ
- គណៈកម្មការត្រួតពិនិត្យបច្ចេកទេសកំណែ
- គណៈកម្មការអប្បមាទមណ្ឌលកំណែ
- គណៈកម្មការក្រុមមុខវិជ្ជា
- គណៈកម្មការផលិតប្លង់ MCS និងផ្គត់ផ្គង់សម្ភារ
- គណៈកម្មការបែងចែងសន្លឹកកិច្ចការ
- គណៈកម្មការកំណែ
- គណៈកម្មការប្រចាំមណ្ឌលកំណែ

- គណៈកម្មការស្រង់ បូកពិន្ទុ ដោយកុំព្យូទ័រ
- គណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល
- គណៈកម្មការគណនេយ្យ និងសម្ភារ
- គណៈកម្មការប្រកាសលទ្ធផល
- គណៈកម្មការកោសល្យវិច័យ
- គណៈកម្មការផ្តល់វិញ្ញាបនបត្របណ្តោះអាសន្ន
- គណៈកម្មការសង្គ្រោះបន្ទាន់មណ្ឌលសំណេរ។

**ប្រការ៦ .-**

ត្រូវបានបង្កើតគណៈមេប្រយោគនិងគណៈកម្មការផ្សេងៗ ដើម្បីរៀបចំនិងគ្រប់គ្រងដំណើរការប្រឡងជ្រើសរើស ប្រឡងបញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀន និងប្រឡងប្រជែង ដើម្បីប្តូរប្រភេទក្របខណ្ឌដូចខាងក្រោម៖

**១. ការប្រឡងជ្រើសរើស:**

- គណៈកម្មការរៀបចំការប្រឡងថ្នាក់កណ្តាល
- គណៈកម្មការរៀបចំការប្រឡងថ្នាក់រាជធានី ខេត្ត
- គណៈកម្មការតាក់តែង និងគ្រប់គ្រងប្រធានវិញ្ញាសា
- គណៈមេប្រយោគទូទាំងប្រទេសពេលសំណេរ
- គណៈកម្មការអប្បមាទពេលសំណេរ
- គណៈមេប្រយោគមណ្ឌល
- គណៈកម្មការកណ្តាល
- គណៈកម្មការអនុរក្ស
- គណៈមេប្រយោគទូទាំងប្រទេសពេលកំណៃ
- គណៈកម្មាការកណ្តាលកំណៃ
- គណៈកម្មការកំណៃ
- គណៈកម្មការត្រួតពិនិត្យកំណៃនិងលទ្ធផល
- គណៈកម្មការគណនេយ្យ និងសម្ភារ។

**២. ការប្រឡងបញ្ចប់:**

- គណៈកម្មការរៀបចំការប្រឡង
- គណៈកម្មការតាក់តែង និងគ្រប់គ្រងប្រធានវិញ្ញាសា
- គណៈមេប្រយោគទូទាំងប្រទេស
- គណៈកម្មការអប្បមាទ
- គណៈមេប្រយោគមណ្ឌល
- គណៈកម្មការកណ្តាល
- គណៈកម្មាការអនុរក្ស
- គណៈកម្មការកំណៃ

- គណៈកម្មការគណនេយ្យនិងសម្ភារ។

**ប្រការ៧ .-**

ត្រូវបានបង្កើតគណៈមេប្រយោគនិងគណៈកម្មការផ្សេងៗ ដើម្បីរៀបចំនិងគ្រប់គ្រងដំណើរការជ្រើសរើស ការប្រឡងជ្រើសរើស ប្រឡងបញ្ចប់ និងការការពារសារណាឬគម្រោងបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា និងការប្រឡងបញ្ចប់ឆ្នាំសិក្សា ប្រឡងសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ នៃវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស វិទ្យាល័យបច្ចេកទេស និងវិទ្យាស្ថានបច្ចេកវិទ្យាក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

**១. ការប្រឡងជ្រើសរើស:**

- គណៈកម្មការទទួលខុសត្រូវរួម
- គណៈកម្មការរៀបចំការប្រឡង
- គណៈកម្មការតាក់តែង និងគ្រប់គ្រងប្រធានវិញ្ញាសា
- គណៈមេប្រយោគសំណេរ (ប្រធាន អនុប្រធាន និងសមាជិកមណ្ឌល)
- គណៈកម្មការកណ្តាលសំណេរ
- គណៈកម្មការអនុរក្ស
- គណៈកម្មការត្រួតពិនិត្យតាមអគារ
- គណៈកម្មការអប្បមាទមណ្ឌលសំណេរ
- គណៈកម្មការប្រឡងវិញ្ញាសាអនុវត្ត
- គណៈមេប្រយោគមណ្ឌលកំណែ (ប្រធាន អនុប្រធាន និងសមាជិកមណ្ឌល)
- គណៈកម្មការកណ្តាលកំណែ
- គណៈកម្មការសួរផ្ទាល់មាត់
- គណៈកម្មការចុះលេខសម្ងាត់
- គណៈកម្មការអប្បមាទមណ្ឌលកំណែ
- គណៈកម្មការកំណែ
- គណៈកម្មការកោសល្យវិច័យ(គណៈកម្មការនេះបង្កើតឡើងនៅពេលមានបញ្ហា)
- គណៈកម្មការគណនេយ្យ និងសម្ភារ។

**២. ការជ្រើសរើស**

- គណៈកម្មការទទួលខុសត្រូវរួម
- គណៈកម្មការគ្រប់គ្រងទូទៅមុនដំណើរការបញ្ចូលទិន្នន័យ (ប្រធាន អនុប្រធាន និងសមាជិក)
    - អនុគណៈកម្មការបញ្ចូលទិន្នន័យបញ្ជីឈ្មោះ និងកូនសៀវភៅចូលក្នុងប្រព័ន្ធកម្មវិធីអាហារូបករណ៍
    - អនុគណៈកម្មការរៀបចំបញ្ជីឈ្មោះ ស្ថិតិ របាយការណ៍ និងផ្ទៀងផ្ទាត់ជាមួយទិន្នន័យ
    - អនុគណៈកម្មការរៀបចំកុំព្យូទ័រ ម៉ាស៊ីនបោះពុម្ព និងតបណ្តាញ

- គណៈកម្មការគ្រប់គ្រងទូទៅក្នុងដំណើរការបញ្ចូលទិន្នន័យ (ប្រធាន អនុប្រធាន និងសមាជិក)
    - អនុគណៈកម្មការគ្រប់គ្រងបច្ចេកទេស
    - អនុគណៈកម្មការបែងចែកសន្លឹកព័ត៌មានបេក្ខជន
    - អនុគណៈកម្មការបញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យកុំព្យូទ័រ
    - អនុគណៈកម្មការផ្ទៀងផ្ទាត់ទិន្នន័យជាមួយសន្លឹកព័ត៌មានបេក្ខជន
- គណៈកម្មការទទួលពាក្យ
- គណៈកម្មការគណនេយ្យ និងសម្ភារ។

**៣. ការប្រឡងបញ្ចប់:**

- គណៈកម្មការទទួលខុសត្រូវរួម
- គណៈកម្មការរៀបចំការប្រឡង
- គណៈកម្មការតាក់តែង និងគ្រប់គ្រងប្រធានវិញ្ញាសា
- គណៈមេប្រយោគសំណេរនិងកំណែ (គណៈមេប្រយោគ គណៈកម្មការកណ្តាល គណៈកម្មការអនុរក្ស និងគណៈកម្មការកំណែ)
- គណៈកម្មការត្រួតពិនិត្យអគារ
- គណៈកម្មការអប្បមាទមណ្ឌលសំណេរនិងកំណែ
- គណៈកម្មការប្រឡងវិញ្ញាសាអនុវត្ត
- គណៈកម្មការសួរផ្ទាល់មាត់
- គណៈកម្មការគណនេយ្យ និងសម្ភារ។

**៤. គណៈកម្មការរៀបចំការការពារសារណាឬគម្រោងបញ្ចប់ការសិក្សាឧត្តមសិក្សា ការការពារសារណារបស់និស្សិត អធិការអប់រំ:**

- គណៈកម្មការមេប្រយោគ
- គណៈកម្មការរៀបចំការការពារសារណាឬគម្រោងបញ្ចប់ការសិក្សា
- គណៈកម្មការការពារសារណាឬគម្រោងបញ្ចប់ការសិក្សា
- គណៈកម្មការកណ្តាល
- គណៈកម្មការគណនេយ្យ និងសម្ភារ។

**ប្រការ៨ .-**

ត្រូវបានបង្កើតគណៈមេប្រយោគនិងគណៈកម្មការផ្សេងៗ ដើម្បីរៀបចំនិងគ្រប់គ្រងដំណើរការប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ទៅបរទេស និងប្រឡងចូលក្របខណ្ឌដូចខាងក្រោម៖

- គណៈកម្មការទទួលខុសត្រូវរួម
- គណៈកម្មការរៀបចំការប្រឡង
- គណៈកម្មការតាក់តែង និងគ្រប់គ្រងប្រធានវិញ្ញាសា
- គណៈកម្មការអប្បមាទ
- គណៈមេប្រយោគសំណេរ (គណៈមេប្រយោគ គណៈកម្មការកណ្តាល គណៈកម្មការអនុរក្ស)

- គណៈមេប្រយោគមណ្ឌលកំណែ (គណៈមេប្រយោគ គណៈកម្មការកណ្តាល គណៈកម្មការចុះលេខសម្ងាត់)
- គណៈកម្មការកំណែ
- គណៈកម្មការគណនេយ្យនិងសម្ភារ។

## ជំពូកទី៣
## ការកំណត់និយាមនិងរយៈពេលបំពេញការងារ
## របស់គណៈមេប្រយោគនិងគណៈកម្មការផ្សេងៗ

**ប្រការ៩ .-**

សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ៖

**១. ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិៈ**

គណៈមេប្រយោគសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិត្រូវរៀបចំតាមនិយាមៈ

- ប្រធាននិងអនុប្រធានមណ្ឌល :នាយកនិងនាយករងដែលទទួលបន្ទុកមធ្យមសិក្សាបឋមភូមិនៃសាលារៀនដែលជាមណ្ឌលប្រឡងទាំងអស់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៩ថ្ងៃ។
- គណៈកម្មការកំណែ : គ្រូបង្រៀនថ្នាក់ទី៩មុខវិជ្ជាប្រឡងនៃសាលារៀនដែលជាមណ្ឌលប្រឡងទាំងអស់និងគិតប្រាក់ឧបត្ថម្ភចំពោះអ្នកកែមុខវិជ្ជាភាសាខ្មែរ (តែងសេចក្តីនិងសរសេរតាមអាន)យ៉ាងច្រើន ៦ថ្ងៃ និងក្រៅពីមុខវិជ្ជាភាសាខ្មែរយ៉ាងច្រើន ០៤ថ្ងៃ។
- គណៈកម្មការផ្សេងៗ : គ្រូបង្រៀនថ្នាក់ទី៩មុខវិជ្ជាមិនប្រឡង គ្រូបង្រៀនថ្នាក់ទី៧និងទី៨គ្រប់មុខវិជ្ជា ព្រមទាំងបុគ្គលិកការិយាល័យ ដែលទទួលបន្ទុកមធ្យមសិក្សាបឋមភូមិនៃសាលារៀនដែលជាមណ្ឌលប្រឡងទាំងអស់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៣ថ្ងៃ។
- គណៈកម្មការគណនេយ្យនិងសម្ភារនៅតាមរាជធានី ខេត្ត ត្រូវរៀបចំតាមនិយាមៈ
  :១នាក់ក្នុងបេក្ខជន២ ០០០នាក់ និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការផ្តល់វិញ្ញាបនបត្របណ្តោះអាសន្ន: ត្រូវទទួលប្រាក់ឧបត្ថម្ភតាមរបបមៅការនិងរៀបចំតាមនិយាមៈ
  - ប្រធាន : ១នាក់

•អនុប្រធាន : ១នាក់

•លេខាធិការ : ១នាក់ក្នុងបេក្ខជន៣ ០០០នាក់ ករណីមានបេក្ខជនក្រោម៣ ០០០នាក់ផ្តល់ជូន១នាក់។

**២. ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ:**

- គណៈកម្មការរៀបចំការប្រឡងនៅថ្នាក់កណ្តាល :ត្រូវរៀបចំតាមនិយាម១នាក់ក្នុងបេក្ខជន១២០០នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការរៀបចំការប្រឡងថ្នាក់រាជធានី ខេត្ត : ត្រូវរៀបចំតាមនិយាម១នាក់ក្នុងបេក្ខជន៣០០០នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការគ្រប់គ្រង គាក់តែងនិងវេចខ្ចប់ប្រធានវិញ្ញាសាៈ ត្រូវទទួលប្រាក់ឧបត្ថម្ភតាមរបបមៅការនិងរៀបចំតាមនិយាមៈ

•ប្រធាន : ១នាក់

•អនុប្រធាន : ១នាក់

•សមាជិកគាក់តែង : ១នាក់ក្នុង១វិញ្ញាសា

•លេខាធិការវេចខ្ចប់ : ១នាក់ក្នុងបេក្ខជន៣០០០នាក់។

- គណៈមេប្រយោគទូទាំងប្រទេស : យ៉ាងច្រើន៥នាក់ក្នុង១រាជធានី ខេត្តនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៨ថ្ងៃ។
- គណៈកម្មការអេប្បមាទទូទាំងប្រទេស :យ៉ាងច្រើន៣នាក់ក្នុង១ មណ្ឌលនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៨ថ្ងៃ។
- គណៈមេប្រយោគមណ្ឌលសំណេរត្រូវរៀបចំតាមនិយាមៈ

•ប្រធានមណ្ឌល : ០១នាក់គិតប្រាក់ឧបត្ថម្ភឱ្យយ៉ាងច្រើន៧ថ្ងៃ។

•អនុប្រធានមណ្ឌល : យ៉ាងច្រើន៤នាក់ក្នុង១មណ្ឌលនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៦ថ្ងៃ។

•គណៈកម្មការត្រួតពិនិត្យតាមអគារ :យ៉ាងច្រើន០.២៥នាក់ក្នុង១បន្ទប់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៣ថ្ងៃ។

•គណៈកម្មការកណ្តាល : យ៉ាងច្រើន០.៥០នាក់ក្នុង១បន្ទប់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៣ថ្ងៃ។

•គណៈកម្មការអនុរក្ស : យ៉ាងច្រើន២.២៥នាក់ក្នុង១បន្ទប់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៣ថ្ងៃ។

- គណៈមេប្រយោគទូទាំងប្រទេសកំណែ : យ៉ាងច្រើន១៩នាក់ និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន២០ថ្ងៃ។
- ប្រធានមណ្ឌលកំណែ : ១នាក់ក្នុង១មណ្ឌលកំណែដោយជ្រើសរើសយកក្នុងចំណោមទូទាំងប្រទេស១៨នាក់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន២០ថ្ងៃ។

- អនុប្រធានមណ្ឌលកំណែ : យ៉ាងច្រើន៣នាក់ក្នុង១មណ្ឌលនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៧ថ្ងៃ។
- គណៈកម្មការកណ្ដាលកំណែ : យ៉ាងច្រើន០.០០៧នាក់ក្នុង១បន្ទប់ក្នុង១មណ្ឌលកំណែនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៧ថ្ងៃ។
- គណៈកម្មការត្រួតពិនិត្យបច្ចេកទេសកំណែ : យ៉ាងច្រើន២៧នាក់ក្នុង១មណ្ឌលកំណែនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៦ថ្ងៃ។
- គណៈកម្មការអប្បមាទកំណែ : យ៉ាងច្រើន១០នាក់ក្នុង១មណ្ឌលកំណែនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៧ថ្ងៃ។
- គណៈកម្មការក្រុមមុខវិជ្ជា : យ៉ាងច្រើន០.០៨នាក់ក្នុង១បន្ទប់ក្នុង១មណ្ឌលកំណែនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៧ថ្ងៃ។
- គណៈកម្មការផលិត ប្ដូរសន្លឹកMCS និងផ្គត់ផ្គង់សម្ភារ : យ៉ាងច្រើន៨នាក់ក្នុង១មណ្ឌលកំណែនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៧ថ្ងៃ។
- គណៈកម្មការបែងចែកសន្លឹកកិច្ចការ : យ៉ាងច្រើន៩០នាក់ក្នុងមួយមណ្ឌលកំណែនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៦ថ្ងៃ។
- គណៈកម្មការកំណែត្រូវរៀបចំតាមនិយាមៈ
    - ប្រធាននិងអនុប្រធាន : យ៉ាងច្រើន០.១៥នាក់នៃអ្នកកែទាំងអស់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៦ថ្ងៃ។
    - អ្នកកែឆ្លងរាជធានី ខេត្ត : ០.៣នាក់ក្នុង១បន្ទប់សម្រាប់មុខវិជ្ជាអក្សរសាស្ត្រខ្មែរ និងគណិតវិទ្យា(២វិញ្ញាសា)និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៥ថ្ងៃ។
    - អ្នកកែមិនឆ្លងរាជធានី ខេត្តៈ០.៣នាក់ក្នុង១បន្ទប់សម្រាប់មុខវិជ្ជាអក្សរសាស្ត្រខ្មែរនិងគណិតវិទ្យា (២វិញ្ញាសា)និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៤ថ្ងៃ។
    - អ្នកកែឆ្លងរាជធានី ខេត្ត : ០.២នាក់ក្នុង១បន្ទប់សម្រាប់មុខវិជ្ជាក្រៅពីអក្សរសាស្ត្រខ្មែរនិងគណិតវិទ្យា(៧វិញ្ញាសា)និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៥ថ្ងៃ។
    - អ្នកកែមិនឆ្លងរាជធានី ខេត្តៈ ០.២នាក់ក្នុង១បន្ទប់សម្រាប់មុខវិជ្ជាក្រៅពីអក្សរសាស្ត្រខ្មែរនិងគណិតវិទ្យា(៧វិញ្ញាសា)និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៤ថ្ងៃ។
- គណៈកម្មការប្រចាំការមណ្ឌលកំណែ : យ៉ាងច្រើន៨នាក់ក្នុងមួយមណ្ឌលកំណែនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៨ថ្ងៃ។
- គណៈកម្មការបូកស្រង់ដោយកុំព្យូទ័រ : យ៉ាងច្រើន៦នាក់ក្នុងកុំព្យូទ័រ១គ្រឿងនិងគិត

ប្រាក់ឧបត្ថម្ភយ៉ាងច្រើន១៣ថ្ងៃ ហើយចំនួនកុំព្យូទ័រស្មើនឹង០.០២៥គ្រឿងក្នុង១បន្ទប់។

- គណៈកម្មការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់លទ្ធផល: យ៉ាងច្រើន០.០១៥នាក់ក្នុង១បន្ទប់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន១៣ថ្ងៃ។
- គណៈកម្មការគណនេយ្យនិងសម្ភារ : ត្រូវរៀបចំតាមនិយាម១នាក់ក្នុងបេក្ខជន២ ០០០នាក់ដោយមានមន្ត្រីតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងតិច១នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបម៉ៅការ។
- គណៈកម្មការប្រកាសលទ្ធផល : គិតនិយាម០.០៨នាក់នៃគណៈកម្មការស្រង់ប៉ូកពិន្ទុ ដោយកុំព្យូទ័រនិងផ្ទៀងផ្ទាត់លទ្ធផលនិងគិតប្រាក់ឧបត្ថម្ភតាមរបបម៉ៅការ។
- គណៈកម្មការកោសល្យវិច័យ(តាមស្ថានភាពជាក់ស្តែង) : ត្រូវទទួលប្រាក់ឧបត្ថម្ភតាមរបបម៉ៅការនិងរៀបចំតាមនិយាម
    - •ប្រធាន : ១នាក់
    - •អនុប្រធាន : យ៉ាងច្រើន៣នាក់
    - •សមាជិក : យ៉ាងច្រើន៣នាក់ក្នុង១មុខវិជ្ជា។
- គណៈកម្មការផ្តល់វិញ្ញាបនបត្របណ្តោះអាសន្ន: ត្រូវទទួលប្រាក់ឧបត្ថម្ភតាមរបបម៉ៅការនិងរៀបចំតាមនិយាមៈ
    - •ប្រធាន : ១នាក់
    - •អនុប្រធាន : ១នាក់
    - •លេខាធិការ : ១នាក់ក្នុងបេក្ខជន៣ ០០០នាក់។
- គណៈកម្មការសង្គ្រោះបន្ទាន់មណ្ឌលសំណេរ : ត្រូវរៀបចំតាមនិយាមយ៉ាងច្រើន៤នាក់ក្នុង១មណ្ឌលសំណេរនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៣ថ្ងៃ។

**ប្រការ១០ .-**

ការប្រឡងជ្រើសរើស ការប្រឡងបញ្ចប់គ្រូបង្រៀន និងការប្រឡងប្តូរប្រភេទក្របខ័ណ្ឌៈ

**១. ការប្រឡងជ្រើសរើសគ្រូនិងការប្រឡងប្តូរប្រភេទក្របខ័ណ្ឌ:**

**ក. ដំណើរការវិញ្ញាសាសរសេរ:**

- គណៈកម្មការរៀបចំការប្រឡងថ្នាក់រដ្ឋបាលកណ្តាល : យ៉ាងច្រើន១៥នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបម៉ៅការ។
- គណៈកម្មការរៀបចំការប្រឡងថ្នាក់រាជធានី ខេត្ត : ត្រូវរៀបចំតាមនិយាម យ៉ាងច្រើន៥នាក់ក្នុង១រាជធានី ខេត្ត និងគិតប្រាក់ឧបត្ថម្ភតាមរបបម៉ៅការ។
- គណៈកម្មការតាក់តែងនិងគ្រប់គ្រងប្រធានវិញ្ញាសា: ត្រូវគិតប្រាក់ឧបត្ថម្ភតាមរបបម៉ៅការនិងរៀបចំតាមនិយាមៈ

•ប្រធាន : ១នាក់
•អនុប្រធាន : ១នាក់
•សមាជិក : ១នាក់ក្នុង១មុខវិជ្ជា
•លេខាធិការ : យ៉ាងច្រើន៣នាក់។

- គណៈមេប្រយោគទូទាំងប្រទេសត្រូវរៀបចំតាមនិយាមៈ
  •ប្រធាន : ១នាក់និងអនុប្រធានយ៉ាងច្រើន២នាក់ដោយគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៧ថ្ងៃ។
  •សមាជិក : យ៉ាងច្រើន២នាក់ក្នុង១រាជធានី ខេត្តដែលមានមណ្ឌលប្រឡងនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៦ថ្ងៃ។
- គណៈកម្មការអប្បមាទ : យ៉ាងច្រើន៣នាក់ក្នុងមួយមណ្ឌលប្រឡងនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៥ថ្ងៃ។
- គណៈមេប្រយោគមណ្ឌលត្រូវរៀបចំតាមនិយាមៈ
  •ប្រធាន : ១នាក់និងអនុប្រធានយ៉ាងច្រើន២នាក់ដោយគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៥ថ្ងៃ។
  •សមាជិក : យ៉ាងច្រើន៣នាក់ក្នុង១មណ្ឌលប្រឡង និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៥ថ្ងៃ។
- គណៈកម្មការកណ្តាល : ត្រូវរៀបចំតាមនិយាម០.៤នាក់ក្នុង១បន្ទប់ឬយ៉ាងតិច៤នាក់ក្នុង១មណ្ឌលនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៥ថ្ងៃ។
- គណៈកម្មការអនុរក្ស : ត្រូវរៀបចំតាមនិយាម២.៥០នាក់ក្នុង១បន្ទប់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៣ថ្ងៃ។
- គណៈកម្មការគណនេយ្យនិងសម្ភារត្រូវរៀបចំតាមនិយាមៈ
  •រដ្ឋបាលកណ្តាល : យ៉ាងច្រើន៩នាក់ដែលក្នុងនោះមានមន្ត្រីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងច្រើន២នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
  •ថ្នាក់រាជធានី ខេត្ត : ១នាក់ក្នុង១រាជធានី ខេត្តនិងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។

**ខ. ដំណើរការកំណែៈ**

- គណៈមេប្រយោគទូទាំងប្រទេសត្រូវរៀបចំតាមនិយាមៈ
  •ប្រធាន : ១នាក់និងអនុប្រធានយ៉ាងច្រើន២នាក់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន១៦ថ្ងៃ។
  •សមាជិក : យ៉ាងច្រើន៣នាក់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន១៥ថ្ងៃ។

- គណៈកម្មការកណ្តាល : ត្រូវរៀបចំតាមនិយាមយ៉ាងច្រើន០.២នាក់ក្នុង ១បន្ទប់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន១៥ថ្ងៃ។
- គណៈកម្មការកំណែត្រូវរៀបចំតាមនិយាមៈ
  - •ប្រធាន : ១នាក់ក្នុង១មុខវិជ្ជាក្នុង១មណ្ឌលនិងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
  - •អនុប្រធាន : ១នាក់ក្នុង១មុខវិជ្ជាក្នុង១មណ្ឌលករណីមានសន្លឹកកិច្ចការលើសពី៤០០គិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
  - •សមាជិក : ១នាក់ក្នុង៤០០សន្លឹកកិច្ចការនិងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការត្រួតពិនិត្យកំណែនិងត្រួតពិនិត្យលទ្ធផលត្រូវរៀបចំតាមនិយាមៈ
  - •ប្រធាន : ១នាក់ និងអនុប្រធាន១នាក់គិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន១០ថ្ងៃ។
  - •សមាជិក : យ៉ាងច្រើន២នាក់ក្នុង១មុខវិជ្ជានិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៩ថ្ងៃ។

**២. ការប្រឡងបញ្ចប់គ្រូបង្រៀន(ចាប់ពីដំណើរការសរសេររហូតដល់ប្រកាសលទ្ធផល):**

- គណៈកម្មការរៀបចំការប្រឡងត្រូវរៀបចំតាមនិយាមៈ យ៉ាងច្រើន១៥នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការតាក់តែងនិងគ្រប់គ្រងប្រធានវិញ្ញាសាៈ ត្រូវគិតប្រាក់ឧបត្ថម្ភតាមរបបមៅការនិងរៀបចំតាមនិយាម
  - •ប្រធាន :១នាក់និងអនុប្រធាន១នាក់
  - •សមាជិក :១នាក់ក្នុង១មុខវិជ្ជា
  - •លេខាធិការ :យ៉ាងច្រើន៣នាក់។
- គណៈមេប្រយោគទូទាំងប្រទេសត្រូវរៀបចំតាមនិយាមៈ
  - •ប្រធាន : ១នាក់និងអនុប្រធាន១នាក់ហើយគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៩ថ្ងៃ។
  - •សមាជិក : យ៉ាងច្រើន២នាក់ក្នុង១មណ្ឌលប្រឡងនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៨ថ្ងៃ។
- គណៈកម្មការអប្បមាទ : យ៉ាងច្រើន៣នាក់ក្នុង១មណ្ឌលប្រឡងនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៧ថ្ងៃ។
- គណៈមេប្រយោគមណ្ឌលត្រូវរៀបចំតាមនិយាមៈ
  - •ប្រធាន : ១នាក់និងអនុប្រធាន១នាក់និងគិតប្រាក់

ឧបត្ថម្ភយ៉ាងច្រើន៧ថ្ងៃ។

•សមាជិក : យ៉ាងច្រើន០.៨នាក់ក្នុង១បន្ទប់ឬយ៉ាងតិច២នាក់ក្នុង១មណ្ឌលនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៦ថ្ងៃ។

- គណៈកម្មការកណ្តាល : ត្រូវរៀបចំតាមនិយាម០.៨នាក់ក្នុង១បន្ទប់ឬយ៉ាងតិច៤នាក់ក្នុង១មណ្ឌលនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៦ថ្ងៃ។
- គណៈកម្មការអនុរក្ស : ត្រូវរៀបចំតាមនិយាម២.៥០នាក់ក្នុង១បន្ទប់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៨ថ្ងៃ។
- គណៈកម្មការកំណែត្រូវគិតប្រាក់ឧបត្ថម្ភតាមរបបមៅការនិងត្រូវរៀបចំតាមនិយាមៈ

•ប្រធាន : ១នាក់ក្នុង១មុខវិជ្ជាក្នុង១មណ្ឌល។

•អនុប្រធាន : ១នាក់ក្នុង១មុខវិជ្ជាក្នុង១មណ្ឌលប្រឡងករណីមានសន្លឹកកិច្ចការលើសពី៨០០។

•សមាជិក : ១នាក់ក្នុង៨០០សន្លឹកកិច្ចការឬ២នាក់យ៉ាងតិចក្នុង១មុខវិជ្ជាក្នុង១មណ្ឌល។

- គណៈកម្មការគណនេយ្យនិងសម្ភារ ត្រូវរៀបចំតាមនិយាមៈ

•រដ្ឋបាលកណ្តាល :យ៉ាងច្រើន៥នាក់ដែលក្នុងនោះមានមន្ត្រីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងច្រើន២នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។

•ថ្នាក់រាជធានី ខេត្ត :១នាក់ក្នុង១រាជធានី ខេត្តនិងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។

**ប្រការ១១ .-**

ការជ្រើសរើស ការប្រឡងជ្រើសរើស ប្រឡងបញ្ចប់ និងការការពារសារណាឬគម្រោងបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា និងការប្រឡងបញ្ចប់ឆ្នាំសិក្សា ប្រឡងសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ នៃវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស វិទ្យាល័យបច្ចេកទេស និងវិទ្យាស្ថានបច្ចេកវិទ្យា ក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ៖

**១. ការប្រឡងជ្រើសរើសៈ**

- គណៈកម្មការទទួលខុសត្រូវរួម : យ៉ាងច្រើន៣នាក់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន១៥ថ្ងៃ។
- គណៈកម្មការរៀបចំការប្រឡង :ត្រូវផ្តល់ប្រាក់ឧបត្ថម្ភតាមរបបមៅការនិងរៀបចំតាមនិយាមៈ

•អនុគណៈកម្មការទទួលពាក្យ
និងវាយបញ្ជីឈ្មោះបេក្ខជន : ១នាក់ក្នុងបេក្ខជន៥០០នាក់ឬ៣នាក់ក្នុងបេក្ខជនក្រោម១០០នាក់ ឬ៥នាក់ក្នុងបេក្ខជនក្រោម៥០០នាក់ក្នុងមួយគ្រឹះស្ថានឧត្តមសិក្សា។

•អនុគណៈកម្មការធ្វើលិខិតបទដ្ឋាននិងកិច្ចការទូទៅៈយ៉ាងច្រើនចំនួន១៥នាក់។

- គណៈកម្មការតាក់តែងនិងគ្រប់គ្រងប្រធានវិញ្ញាសា ៈត្រូវផ្តល់ប្រាក់ឧបត្ថម្ភតាមរបបមៅការនិង រៀបចំតាមនិយាមៈ

•ប្រធាន ៈ ១នាក់និងអនុប្រធាន១នាក់

•សមាជិក ៈ ១នាក់ក្នុង១មុខវិជ្ជាឬយ៉ាងច្រើន២នាក់ក្នុង ១មុខវិជ្ជា

•លេខាធិការ ៈ ៣នាក់ចំពោះបេក្ខជនក្រោម១០០នាក់ ឬ៥ នាក់ចំពោះបេក្ខជនក្រោម៥០០នាក់ និងថែម១ នាក់ក្នុងបេក្ខជន៥០០នាក់។

- គណៈមេប្រយោគមណ្ឌលសំណេរ ត្រូវរៀបចំតាមនិយាមៈ

•គណៈមេប្រយោគ ៈ យ៉ាងច្រើន៥នាក់ក្នុង១មណ្ឌលនិងគិតប្រាក់ ឧបត្ថម្ភយ៉ាងច្រើនចំនួន៣ថ្ងៃ។

•គណៈកម្មការកណ្តាល ៈ យ៉ាងច្រើន០.៥នាក់ក្នុង១បន្ទប់ឬយ៉ាងតិច៥ នាក់ ក្នុង១មណ្ឌល និងគិតប្រាក់ឧបត្ថម្ភយ៉ាង ច្រើនចំនួន២ថ្ងៃ។

•គណៈកម្មការអនុរក្ស ៈ យ៉ាងច្រើន២.២៥នាក់ ក្នុង១បន្ទប់ និងគិត ប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន២ថ្ងៃ។

•គណៈកម្មការត្រួតពិនិត្យ តាមអគារ ៈ យ៉ាងច្រើន០.២៥នាក់ក្នុង១បន្ទប់និងគិតប្រាក់ ឧបត្ថម្ភយ៉ាងច្រើនចំនួន២ថ្ងៃ។

- គណៈកម្មការអប្បមាទមណ្ឌលសំណេរ ៈ យ៉ាងច្រើន៣នាក់ក្នុង១មណ្ឌល និងគិត ប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន៣ថ្ងៃ។

- គណៈកម្មការប្រឡងវិញ្ញាសាអនុវត្ត ត្រូវរៀបចំតាមនិយាមៈ

•ប្រធាន ៈ ១នាក់និងអនុប្រធាន១នាក់ទទួលខុសត្រូវរួម និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៦ថ្ងៃ

•សមាជិក ៈ ១នាក់ក្នុងបេក្ខជន១០០នាក់ក្នុង១ វិញ្ញាសា អនុវត្តនិងតិចបំផុត៣នាក់ក្នុង១វិញ្ញាសា និង គិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៦ថ្ងៃ។

- គណៈមេប្រយោគមណ្ឌលកំណែត្រូវរៀបចំតាមនិយាមៈ

•គណៈមេប្រយោគ ៈ យ៉ាងច្រើន៣នាក់ក្នុង១មណ្ឌលនិងគិតប្រាក់ ឧបត្ថម្ភយ៉ាងច្រើនចំនួន១២ថ្ងៃ។ ដោយឡែក ចំពោះការប្រឡងជ្រើសរើសគរុនិស្សិត(បរិញ្ញា+១) ចាប់ពី៨០០០នាក់ឡើងទៅ ត្រូវគិតប្រាក់ឧបត្ថម្ភ ចំនួន១៦ថ្ងៃ។

- •គណៈកម្មការកណ្តាល : ចំនួន៤នាក់ក្នុង១មណ្ឌលចំពោះមណ្ឌលដែលតិចជាង១០បន្ទប់ឬ០.៥នាក់ក្នុង១បន្ទប់ចំពោះមណ្ឌលដែលមានពី១០ទៅ៣០បន្ទប់ ឬ០.៣នាក់ក្នុង១បន្ទប់ ចំពោះមណ្ឌលដែលមានចាប់ពី៣០បន្ទប់ឡើងទៅនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន១១ថ្ងៃ។ ដោយឡែកចំពោះការប្រឡងជ្រើសរើសគរុនិស្សិត(បរិញ្ញា+១)ចាប់ពី៨០០០នាក់ឡើងទៅត្រូវគិតប្រាក់ឧបត្ថម្ភចំនួន១៥ថ្ងៃ។
- •គណៈកម្មការចុះលេខសំងាត់: យ៉ាងច្រើន២នាក់ក្នុង១មណ្ឌល និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន១១ថ្ងៃ។ ដោយឡែកចំពោះការប្រឡងជ្រើសរើសគរុនិស្សិត(បរិញ្ញា+១) ចាប់ពី៨០០០នាក់ឡើងទៅ ត្រូវគិតប្រាក់ឧបត្ថម្ភចំនួន១៥ថ្ងៃ។

- គណៈកម្មការអប្បមាទមណ្ឌលកំណៃ :យ៉ាងច្រើន៣នាក់ក្នុង១មណ្ឌល និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន១២ថ្ងៃ។ ដោយឡែកចំពោះការប្រឡងជ្រើសរើសគរុនិស្សិត(បរិញ្ញា+១) ចាប់ពី៨០០០នាក់ឡើងទៅ ត្រូវគិតប្រាក់ឧបត្ថម្ភចំនួន១៦ថ្ងៃ។
- គណៈកម្មការកំណៃត្រូវគិតប្រាក់ឧបត្ថម្ភតាមរបបមៅការនិងត្រូវរៀបចំតាមនិយាម:
  - •ប្រធាន : ១នាក់ក្នុង១មុខវិជ្ជាក្នុង១មណ្ឌល។
  - •អនុប្រធាន : ១នាក់ក្នុង១មុខវិជ្ជាក្នុងមណ្ឌលក្នុងករណីមានសន្លឹកកិច្ចការលើសពី៤០០។
  - •សមាជិក : ១នាក់ក្នុង៤០០សន្លឹកកិច្ចការឬ២នាក់យ៉ាងតិចក្នុង១មុខវិជ្ជាក្នុង១មណ្ឌលយ៉ាងតិច។
- គណៈកម្មការកោសល្យវិច័យ(ករណីចាំបាច់) : យ៉ាងច្រើន២នាក់ក្នុង១មុខវិជ្ជានិងត្រូវគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការគណនេយ្យ និងសម្ភារ : យ៉ាងច្រើន៣នាក់ក្នុង១មណ្ឌល ក្នុងនោះមានមន្ត្រីតំណាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនាក់ និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។

**២. ការជ្រើសរើស:**

- គណៈកម្មការទទួលខុសត្រូវរួម : ១នាក់ក្នុង១០កុំព្យូទ័រឬយ៉ាងច្រើន៣នាក់ និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន១៥ថ្ងៃ។

- គណៈកម្មការគ្រប់គ្រងទូទៅមុនដំណើរការបញ្ចូលទិន្នន័យ : ១នាក់ក្នុង១០០វិទ្យាល័យ យ៉ាងច្រើន៥នាក់ និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
    - អនុគណៈកម្មការបញ្ចូលទិន្នន័យបញ្ជីឈ្មោះ និងកូនសៀវភៅចូលក្នុងប្រព័ន្ធកម្មវិធីអាហារូបករណ៍ : ១នាក់ក្នុង៥០វិទ្យាល័យ ឬយ៉ាងច្រើន១០នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
    - អនុគណៈកម្មការរៀបចំបញ្ជីឈ្មោះស្ថិតិរបាយការណ៍និងផ្ទៀងផ្ទាត់ជាមួយទិន្នន័យ : ១នាក់ក្នុង៥០វិទ្យាល័យ ឬយ៉ាងច្រើន១០នាក់ និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
    - អនុគណៈកម្មការរៀបចំកុំព្យូទ័រម៉ាស៊ីនបោះពុម្ពនិងតបណ្ដាញ: ១នាក់ក្នុង៨កុំព្យូទ័រ ឬយ៉ាងច្រើន១០នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការគ្រប់គ្រងទូទៅក្នុងដំណើរការបញ្ចូលទិន្នន័យ : ១នាក់ក្នុង០៨កុំព្យូទ័រឬយ៉ាងច្រើន៥នាក់និងគិតប្រាក់យ៉ាងច្រើន១៥ថ្ងៃ។
    - អនុគណៈកម្មការគ្រប់គ្រងបច្ចេកទេស : ១នាក់ក្នុង០៨កុំព្យូទ័រ ឬយ៉ាងច្រើន១០នាក់ និងគិតប្រាក់យ៉ាងច្រើន១៤ថ្ងៃ។
    - អនុគណៈកម្មការបែងចែកសន្លឹកព័ត៌មានបេក្ខជន : ១នាក់ក្នុង៦ ០០០សន្លឹកព័ត៌មាន ឬយ៉ាងច្រើន ១២នាក់ និងគិតប្រាក់យ៉ាងច្រើន១៤ថ្ងៃ។
    - អនុគណៈកម្មការបញ្ចូលនិងផ្ទៀងផ្ទាត់ទិន្នន័យកុំព្យូទ័រ : ១នាក់ក្នុង១ ២០០សន្លឹកព័ត៌មានឬយ៉ាងច្រើន ៦០នាក់និងគិតប្រាក់យ៉ាងច្រើន១៤ថ្ងៃ។
    - អនុគណៈកម្មការផ្ទៀងផ្ទាត់ទិន្នន័យជាមួយសន្លឹកព័ត៌មានបេក្ខជន: ១នាក់ក្នុង២ ០០០សន្លឹកព័ត៌មានឬយ៉ាងច្រើន ៣០នាក់និងគិតប្រាក់យ៉ាងច្រើន១៤ថ្ងៃ។
- គណៈកម្មការទទួលពាក្យ : ២នាក់ក្នុង១វិទ្យាល័យ ឬយ៉ាងច្រើន១០នាក់ក្នុង ១ដេប៉ាតឺម៉ង់និងគិតប្រាក់តាមរបបមៅការ។

- គណៈកម្មការគណនេយ្យ និងសម្ភារ : យ៉ាងច្រើន៥នាក់ក្នុង១គ្រឹះស្ថាន ដែលមានមន្ត្រីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងតិច១នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។

**៣. ការប្រឡងបញ្ចប់:**

- គណៈកម្មការទទួលខុសត្រូវរួម : យ៉ាងច្រើន៣នាក់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន១២ថ្ងៃ។
- គណៈកម្មការរៀបចំការប្រឡង : យ៉ាងច្រើន៥នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការគ្រប់គ្រងនិងតាក់តែងប្រធានវិញ្ញាសា : ត្រូវផ្តល់ប្រាក់ឧបត្ថម្ភតាមរបបមៅការនិងរៀបចំតាមនិយាម
  - •ប្រធាន : ១នាក់និងអនុប្រធាន១នាក់
  - •សមាជិក : យ៉ាងច្រើន៣នាក់ក្នុង១មុខវិជ្ជា
  - •លេខាធិការ : យ៉ាងច្រើន៥នាក់។
- គណៈមេប្រយោគសំណេរនិងកំណែត្រូវរៀបចំតាមនិយាម:
  - •គណៈមេប្រយោគ : យ៉ាងច្រើន៣នាក់ក្នុង១មណ្ឌលនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន១២ថ្ងៃ។
  - •គណៈកម្មការកណ្តាល : យ៉ាងច្រើន.០៥នាក់ក្នុង១បន្ទប់ឬយ៉ាងតិច៥នាក់ក្នុង១មណ្ឌល និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន១២ថ្ងៃ។
  - •គណៈកម្មការអនុរក្ស : យ៉ាងច្រើន២.៥០នាក់ក្នុង១បន្ទប់និងគិប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន៥ថ្ងៃ។
- គណៈកម្មការកំណែត្រូវគិតប្រាក់ឧបត្ថម្ភតាមរបបមៅការនិងត្រូវរៀបចំតាមនិយាម:
  - •ប្រធាន : ១នាក់ក្នុង១មុខវិជ្ជាក្នុង១មណ្ឌល។
  - •អនុប្រធាន : ១នាក់ក្នុង១មុខវិជ្ជាក្នុងមណ្ឌលក្នុងករណីមានសន្លឹកកិច្ចការលើសពី៤០០។
  - •សមាជិក : ១នាក់ក្នុង៤០០សន្លឹកកិច្ចការឬ២នាក់យ៉ាងតិចក្នុង១មុខវិជ្ជាក្នុង១មណ្ឌល។
- គណៈកម្មការអប្បមាទមណ្ឌលសំណេរនិងកំណែ : យ៉ាងច្រើន៣នាក់ក្នុង១មណ្ឌលនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន១២ថ្ងៃ។
- គណៈកម្មការប្រឡងវិញ្ញាសាអនុវត្ត : យ៉ាងច្រើន៣នាក់ក្នុង១វិញ្ញាសានិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន៥ថ្ងៃ។
- គណៈកម្មការគណនេយ្យ និងសម្ភារ : យ៉ាងច្រើន៣នាក់ក្នុង១មណ្ឌលក្នុងនោះមានមន្ត្រីតំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ១នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។

**ប្រការ១២ .-**

ការពារសារណាឬការការពារគម្រោងបញ្ចប់ការសិក្សា

- គណៈកម្មការមេប្រយោគ : យ៉ាងច្រើន៣នាក់ក្នុងបេក្ខជន១នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការរៀបចំ : យ៉ាងច្រើន៧នាក់និងប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការការពារសារណា : យ៉ាងច្រើន៥នាក់ក្នុងបេក្ខជន១នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការកណ្តាល : យ៉ាងច្រើន៥នាក់ និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការគណនេយ្យ និងសម្ភារ : យ៉ាងច្រើន៣នាក់ក្នុង១មណ្ឌលក្នុងនោះមានមន្ត្រីតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១នាក់ និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។

**ប្រការ១៣ .-**

ប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ទៅសិក្សានៅបរទេសនិងចូលក្របខ័ណ្ឌ:

- គណៈកម្មការទទួលខុសត្រូវរួម : យ៉ាងច្រើន៣នាក់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើន៩ថ្ងៃ។
- គណៈកម្មការរៀបចំការប្រឡង : យ៉ាងច្រើន១២នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការគ្រប់គ្រងនិងតាក់តែងប្រធានវិញ្ញាសា:ត្រូវផ្តល់ប្រាក់ឧបត្ថម្ភតាមរបបមៅការនិងរៀបចំតាមនិយាម:
  - ប្រធាន : ១នាក់និងអនុប្រធាន១នាក់
  - សមាជិក : យ៉ាងច្រើន២នាក់ក្នុង១មុខវិជ្ជា
  - លេខាធិការ : យ៉ាងច្រើន៧នាក់អាស្រ័យចំនួនវិញ្ញាសា។
- គណៈកម្មការអប្បមាទមណ្ឌល : យ៉ាងច្រើន៥នាក់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន៩ថ្ងៃ។
- គណៈមេប្រយោគសំណេរត្រូវរៀបចំតាមនិយាម:
  - គណៈមេប្រយោគ : យ៉ាងច្រើន៥នាក់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន៣ថ្ងៃ។
  - គណៈកម្មការកណ្តាល : យ៉ាងច្រើន.០៥នាក់ក្នុង១បន្ទប់ឬយ៉ាងតិច៥នាក់ក្នុង១មណ្ឌលនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន២ថ្ងៃ។

•គណៈកម្មការអនុរក្ស : យ៉ាងច្រើន២.៥០នាក់ក្នុង១បន្ទប់និងគិតប្រាក់ឧបត្ថម្ភទៅតាមចំនួនថ្ងៃជាក់ស្តែងនៃប្រទេសផ្តល់អាហារូបករណ៍។

- គណៈមេប្រយោគមណ្ឌលកំណែត្រូវរៀបចំតាមនិយាមៈ
  - •គណៈមេប្រយោគ : យ៉ាងច្រើន៥នាក់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន៧ថ្ងៃ។
  - •គណៈកម្មការកណ្តាល : យ៉ាងច្រើន០.៤នាក់ក្នុង១បន្ទប់ឬយ៉ាងតិច៥នាក់ក្នុង១មណ្ឌលនិងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន៧ថ្ងៃ។
  - •គណៈកម្មការចុះលេខសម្ងាត់: ១នាក់និងគិតប្រាក់ឧបត្ថម្ភយ៉ាងច្រើនចំនួន៧ថ្ងៃ។
- គណៈកម្មការកំណែត្រូវរៀបចំតាមនិយាមៈ
  - •ប្រធាន : ១នាក់ក្នុង១មុខវិជ្ជាក្នុង១មណ្ឌលត្រូវគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
  - •អនុប្រធាន : ១នាក់ក្នុង១មុខវិជ្ជា ក្នុងករណីមានសន្លឹកកិច្ចការលើសពី៤០០ត្រូវគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
  - •សមាជិក : យ៉ាងច្រើន១នាក់ក្នុង៤០០សន្លឹកកិច្ចការឬ២នាក់យ៉ាងតិចក្នុង១មុខវិជ្ជាក្នុង១មណ្ឌលត្រូវគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការកោសល្យវិច័យ(ករណីចាំបាច់) : យ៉ាងច្រើន២នាក់ក្នុង១មុខវិជ្ជានិងត្រូវគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។
- គណៈកម្មការគណនេយ្យ និងសម្ភារ : យ៉ាងច្រើន៥នាក់ក្នុង១មណ្ឌលក្នុងនោះមានមន្ត្រីតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងតិច១នាក់និងគិតប្រាក់ឧបត្ថម្ភតាមរបបមៅការ។

## ជំពូកទី៤
## ការកំណត់ប្រាក់ឧបត្ថម្ភគណៈមេប្រយោគនិងគណៈកម្មការផ្សេងៗ

**ប្រការ១៤ .-**

ចំពោះការប្រឡងជ្រើសរើស ការជ្រើសរើស និងការប្រឡងបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានសិក្សានីមួយៗ អាចបង្កើតគណៈកម្មការដែលទទួលប្រាក់ឧបត្ថម្ភតាមរបបមៅការបានតែម្តងគត់ក្នុងសម័យប្រឡង១លើកឬច្រើនលើកបើពេលប្រឡងត្រួតគ្នា។

**ប្រការ១៥ .-**

ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ ដែលបានចាត់តាំងឱ្យចូលរួមក្នុងដំណើរការប្រឡងអាចទទួលប្រាក់ឧបត្ថម្ភបានតែម្តងគត់ក្នុងដំណាក់កាលនីមួយៗនៃសម័យប្រឡងមួយលើកឬច្រើនលើកបើពេលប្រឡងត្រូវគ្នា លើកលែងតែការចូលរួមក្នុងដំណើរការតាក់តែងប្រធានវិញ្ញាសា។

**ប្រការ១៦ .-**

គណៈកម្មការគណនេយ្យនិងសម្ភារនិងអ្នកបើកបរអាចទទួលប្រាក់ឧបត្ថម្ភតែម្តងគត់ក្នុងសម័យប្រឡងមួយលើកឬច្រើនលើកបើពេលប្រឡងត្រូវគ្នា។

**ប្រការ១៧ .-**

គណៈកម្មការនីមួយៗ ដែលទទួលបានប្រាក់ឧបត្ថម្ភណាមួយរួចហើយក្នុងលិខិតឧទ្ទេសនាមមិនត្រូវអនុញ្ញាតឱ្យប្រើប្រាស់ថវិកាបេសកកម្មដទៃទៀតឡើយ។

**ប្រការ១៨ .-**

ប្រាក់ឧបត្ថម្ភការប្រឡងត្រូវបានកំណត់ដូចខាងក្រោម:

១. ចំពោះមន្ត្រីរាជការដែលចូលរួមគណៈកម្មការប្រឡងក្រៅពីគណៈកម្មការ ដែលទទួលប្រាក់ឧបត្ថម្ភតាមរបបមៅការ÷

**ក.**ប្រាក់ឧបត្ថម្ភគណៈកម្មការមិនឆ្លងក្រុង ស្រុក ខណ្ឌត្រូវបានទទួលប្រាក់ឧបត្ថម្ភចំនួន**៥៧.០០០រៀល** ក្នុង១ថ្ងៃសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ។

**ខ.**ប្រាក់ឧបត្ថម្ភគណៈកម្មការមិនឆ្លងក្រុង ស្រុក ខណ្ឌត្រូវបានទទួលប្រាក់ឧបត្ថម្ភចំនួន**៩៥.០០០រៀល** ក្នុង១ថ្ងៃ។

**គ.** ប្រាក់ឧបត្ថម្ភគណៈកម្មការឆ្លងក្រុង ស្រុក ខណ្ឌត្រូវបានទទួលប្រាក់ឧបត្ថម្ភចំនួន**១៩១.០០០រៀល** ក្នុង១ថ្ងៃនិងមធ្យោបាយធ្វើដំណើរទៅមកតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា។

**ឃ.** សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មេប្រយោគដែលធ្វើដំណើរពីថ្នាក់កណ្តាលទៅបំពេញការងារនៅខេត្តរតនៈគិរីត្រូវបានឧបត្ថម្ភបន្ថែមចំនួន៤០០.០០០រៀលក្នុង១នាក់។ ដោយឡែក មេប្រយោគដែលធ្វើដំណើរពីថ្នាក់កណ្តាលទៅបំពេញការងារនៅខេត្តកោះកុង មណ្ឌលគិរី ព្រះវិហារ ស្ទឹងត្រែង ឧត្តរមានជ័យ បន្ទាយមានជ័យ និងប៉ៃលិន ត្រូវបានឧបត្ថម្ភបន្ថែមចំនួន២០០.០០០រៀលក្នុង១នាក់។

២. ចំពោះគណៈកម្មការប្រឡង ដែលទទួលប្រាក់ឧបត្ថម្ភតាមរបបមៅការនិងការចំណាយផ្សេងៗ ត្រូវអនុវត្តតាមអត្រាដូចមានចែងក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | គ្រឹះស្ថានឧត្តមសិក្សា និងមធ្យមបច្ចេកទេស | គ្រូ+ប្តូរប្រភេទ ក្របខ័ណ្ឌ | អាហារូបករណ៍+ចូលក្របខ័ណ្ឌ | មធ្យសិក្សាចំណេះទូទៅ |
|---|---|---|---|---|---|
| ១ | គណៈកម្មការគ្រប់គ្រង និងតាក់តែងវិញ្ញាសា:<br>-ប្រធាន និងអនុប្រធាន<br>-សមាជិក<br><br>-លេខាធិការពេលធ្វើវិញ្ញាសា<br>-កម្រៃឧបត្ថម្ភប្រចាំការពេលធ្វើវិញ្ញាសា | ១.៥០០.០០០/ម្នាក់<br>១.២០០.០០០/វិញ្ញាសាឬ ៧០០.០០០ /ម្នាក់<br>៦៥០.០០០/ម្នាក់<br>៨០.០០០/ម្នាក់ (ថ្ងៃនិងយប់) | ១.៥០០.០០០/ម្នាក់<br>១.២០០.០០០/វិញ្ញាសាឬ ៧០០.០០០ /ម្នាក់<br>៦៥០.០០០/ម្នាក់<br>៨០.០០០/ម្នាក់ (ថ្ងៃនិងយប់) | ១.៥០០.០០០/ម្នាក់<br>១.២០០.០០០/វិញ្ញាសា ឬ ៧០០.០០០ /ម្នាក់<br>៦៥០.០០០/ម្នាក់<br>៨០.០០០/ម្នាក់ (ថ្ងៃនិងយប់) | ១.៥០០.០០០/ម្នាក់<br>១.២០០.០០០/វិញ្ញាសា<br>៦៥០.០០០/ម្នាក់ |

| | | | | | |
|---|---|---|---|---|---|
| ២ | គណៈកម្មការរៀបចំការប្រឡង:<br>-រដ្ឋបាលកណ្តាល<br>-រាជធានី ខេត្ត<br>-អ្នកបើកបរ(ពេលសំណេរដល់ប្រកាសលទ្ធផល) | ៤០០.០០០៛/ម្នាក់<br>២០០.០០០៛/ម្នាក់<br>៣០០.០០០៛/ម្នាក់ | ៤០០.០០០៛/ម្នាក់<br>២០០.០០០៛/ម្នាក់<br>៥០០.០០០៛/ម្នាក់ | ៤០០.០០០៛/ម្នាក់<br><br>៣០០.០០០៛/ម្នាក់ | ៦៥០.០០០៛/ម្នាក់<br>៥០០.០០០៛/ម្នាក់<br>៥០០.០០០៛/ម្នាក់ |
| ៣ | គណៈកម្មការកំណែ:<br>-កម្រៃអត្រាកំណែ<br>-កម្រៃកែកិច្ចការ<br><br>-ប្រធាន+អនុប្រធានកំណែ | ៦០.០០០៛/ម្នាក់<br>៣.៥០០៛/កិច្ចការឬ<br>៦.០០០៛/កិច្ចការបើចំនួនកិច្ចការតិចជាង១០០<br>ប្រាក់ឧបត្ថម្ភស្មើនឹងកម្រៃកំណែមធ្យមនៃអ្នកកែសរុប | ៦០.០០០៛/ម្នាក់<br>៣.៥០០៛/កិច្ចការឬ<br>៦.០០០៛/កិច្ចការបើចំនួនកិច្ចការតិចជាង១០០<br>ប្រាក់ឧបត្ថម្ភស្មើនឹងកម្រៃកំណែមធ្យមនៃអ្នកកែសរុប | ៦០.០០០៛/ម្នាក់<br>៣.៥០០៛/កិច្ចការឬ<br>៦.០០០៛/កិច្ចការបើចំនួនកិច្ចការតិចជាង១០០<br>ប្រាក់ឧបត្ថម្ភស្មើនឹងកម្រៃកំណែមធ្យមនៃអ្នកកែសរុប | |
| ៤ | គណៈកម្មការគោសល្យវិច័យ | ៦.០០០៛/កិច្ចការ | ៦.០០០៛/កិច្ចការ | ៦.០០០៛/កិច្ចការ | ៦.០០០៛/កិច្ចការ |
| ៥ | គណៈកម្មការគណនេយ្យនិងសម្ភារៈ<br>-ប្រធាន<br>-អនុប្រធាន<br>-សមាជិក | ៦០០.០០០៛/ម្នាក់<br>៦០០.០០០៛/ម្នាក់<br>៦០០.០០០៛/ម្នាក់ | ៦០០.០០០៛/ម្នាក់<br>៦០០.០០០៛/ម្នាក់<br>៦០០.០០០៛/ម្នាក់ | ៦០០.០០០៛/ម្នាក់<br>៦០០.០០០៛/ម្នាក់<br>៦០០.០០០៛/ម្នាក់ | ១.៥០០.០០០៛/ម្នាក់<br>១.៣០០.០០០៛/ម្នាក់<br>១.២០០.០០០៛/ម្នាក់ឬ<br>៥០០.០០០៛/ម្នាក់សម្រាប់មធ្យមសិក្សាបឋមភូមិ |
| ៦ | កម្រៃឧបត្ថម្ភប្រចាំការពេលប្រកាសលទ្ធផល | ១០.០០០៛/ម្នាក់ | ១០.០០០៛/ម្នាក់ | ១០.០០០៛/ម្នាក់ | ១០.០០០៛/ម្នាក់ |
| ៧ | ចំណាយសម្រាប់សុវត្ថិភាព:<br>**ក**-មណ្ឌលសំណេរ:<br>-មណ្ឌលតូច(តិចជាង២០បន្ទប់)<br>-មណ្ឌលធំ(ចាប់ពី២០បន្ទប់ឡើងទៅ)<br>**ខ**-មណ្ឌលវិញ្ញាសា:<br>**គ**-មណ្ឌលស្រង់ ឬកពិន្ទុកដោយកុំព្យូទ័រ<br>**ឃ**-មណ្ឌលកំណែ:<br>-មណ្ឌលតូច(តិចជាង២០បន្ទប់)<br>-មណ្ឌលធំ(ចាប់ពី២០បន្ទប់ឡើង) | <br><br>៦០០.០០០៛/មណ្ឌល<br>៨០០.០០០៛/មណ្ឌល<br>២០០.០០០៛/មណ្ឌល<br><br><br>៨០០.០០០៛/មណ្ឌល<br>១.០០០.០០០៛/មណ្ឌល | <br><br>៦០០.០០០៛/មណ្ឌល<br>១.០០០.០០០៛/មណ្ឌល<br>៨០០.០០០៛/មណ្ឌល<br><br><br>៨០០.០០០៛/មណ្ឌល<br>២.០០០.០០០៛/មណ្ឌល | <br><br>៦០០.០០០៛/មណ្ឌល<br>៨០០.០០០៛/មណ្ឌល<br>២០០.០០០៛/មណ្ឌល<br><br><br>៨០០.០០០៛/មណ្ឌល<br>១.០០០.០០០៛/មណ្ឌល | <br><br>៦០០.០០០៛/មណ្ឌល<br>១.០០០.០០០៛/មណ្ឌល<br>២.០០០.០០០០៛/មណ្ឌល<br>១.០០០..០០០៛/មណ្ឌល<br><br>៨០០..០០០៛/មណ្ឌល<br>១.២០០..០០០៛/មណ្ឌល |
| ៨ | គណៈកម្មការមេប្រយោគការពារសាលាណា | ៤០០.០០០៛/ម្នាក់ | | | |
| ៩ | គណៈកម្មការការពារសោរណា | ២០០.០០០៛/បេក្ខជន/ម្នាក់ | | | |
| ១០ | គណៈកម្មការកណ្តាលការពារសាលាណា | ៤០០.០០០៛/ម្នាក់ | | | |
| ១១ | គណៈកម្មការសួរផ្ទាល់មាត់ | ៥.០០០៛/បេក្ខជនម្នាក់ | | | |
| ១២ | គណៈកម្មការគ្រប់គ្រងទូទៅមុនដំណើរការបញ្ចូលទិន្នន័យ | ៤០០.០០០៛/ម្នាក់ | | | |
| ១៣ | អនុគណៈកម្មការផ្ទៀងផ្ទាត់ស្នាមហត្ថលេខាពីបញ្ជីឈ្មោះនិងកូនសៀវភៅចូលក្នុងដាតាបេស | ៤០០.០០០៛/ម្នាក់ | | | |
| ១៤ | អនុគណៈកម្មការរៀបចំបញ្ជីឈ្មោះស្ថិតិរបាយការណ៍និងផ្ទៀងផ្ទាត់ជាមួយស្នាមហត្ថលេខាពី | ៤០០.០០០៛/ម្នាក់ | | | |
| ១៥ | អនុគណៈកម្មការរៀបចំកុំព្យូទ័រម៉ាស៊ីនព្រីននិងតបណ្តាញណេតវើក | ៤០០.០០០៛/ម្នាក់ | | | |

| | | | | | |
|---|---|---|---|---|---|
| ១៦ | សោហ៊ុយខេត្ត-ក្រុងដឹកសម្ភារនិងឯកសារប្រឡងក្នុងនោះ:<br>-រាជធានីភ្នំពេញ(សម្រាប់ប្រឡង១ដង)<br>-ខេត្តកណ្តាល(សម្រាប់ប្រឡង១ដង)<br>-ខេត្តកំពង់ស្ពឺ តាកែវ កំពត កែប ព្រះសីហនុ កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង សៀមរាប កំពង់ចាម កំពង់ធំ ស្វាយរៀង ព្រៃវែង ក្រចេះ និងត្បូងឃ្មុំ<br>(សម្រាប់ប្រឡង១ដង)<br>-ខេត្តព្រះវិហារ រតនគីរី មណ្ឌលគីរី ស្ទឹងត្រែង កោះកុង បន្ទាយមានជ័យ ប៉ៃលិន និងខេត្តឧត្តរមានជ័យ<br>(សម្រាប់ប្រឡង១ដង) | ១០០.០០០/មណ្ឌល | ១៦០.០០០/រាជធានី<br>២៨០.០០០/ខេត្ត<br>៦០០.០០០/ខេត្ត<br>១.០០០.០០០/ខេត្ត | | ១៦០.០០០/រាជធានី<br>២៨០.០០០/ខេត្ត<br>៦០០.០០០/ខេត្ត<br>១.០០០.០០០/ខេត្ត |
| ១៧ | សោហ៊ុយដឹកប្រធានវិញ្ញាសាពីភ្នំពេញទៅមករាជធានី ខេត្តក្នុងនោះ:<br>-រាជធានីភ្នំពេញ(សម្រាប់ប្រឡង១ដង)<br>-ខេត្តកណ្តាល(សម្រាប់ប្រឡង១ដង)<br>-ខេត្តកំពង់ស្ពឺ តាកែវ កំពត កែប ព្រះសីហនុ កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង សៀមរាប កំពង់ចាម កំពង់ធំ ស្វាយរៀង ព្រៃវែង ក្រចេះ និងត្បូងឃ្មុំ<br>(សម្រាប់ប្រឡង១ដង)<br>-ខេត្តព្រះវិហារ រតនគីរី មណ្ឌលគីរី ស្ទឹងត្រែង កោះកុង បន្ទាយមានជ័យ ប៉ៃលិន និងខេត្តឧត្តរមានជ័យ<br>(សម្រាប់ប្រឡង១ដង) | | ៥០.០០០/មណ្ឌល<br>៦០.០០០/មណ្ឌល<br>៨០.០០០/មណ្ឌល<br>១០០.០០០/មណ្ឌល | | ៨០.០០០/មណ្ឌល<br>១២០.០០០/មណ្ឌល<br>១៨០.០០០/មណ្ឌ<br>៣៨០.០០០/មណ្ឌល |
| ១៨ | សោហ៊ុយដឹកប្រធានវិញ្ញាសាពីរាជធានី ខេត្ត ទៅមណ្ឌលប្រឡង | ៥០.០០០/មណ្ឌល | | | ២០០.០០០/មណ្ឌល |
| ១៩ | គណៈកម្មការផ្តល់វិញ្ញាបនបត្របណ្តោះអាសន្ន:<br>-ប្រធាននិងអនុប្រធាន<br>-លេខាធិការ | | | | ១.៥០០.០០០/ម្នាក់<br>៦៥០.០០០/ម្នា |
| ២០ | បន្ថែមលើមធ្យោបាយធ្វើដំណើរទៅមកតាមយន្តហោះកប៉ាល់និងរថយន្ត ។ | មិនចាំបាច់មាន សក្ខីបត្រចំណាយ | មិនចាំបាច់មាន សក្ខីបត្រចំណាយ | | មិនចាំបាច់មាន សក្ខីបត្រចំណាយ |

## ជំពូកទី៥
## អវសានបញ្ញត្តិ

**ប្រការ១៩ .-**

ប្រកាសអន្តរក្រសួងលេខ ៥០៥ សហវ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០១ ស្តីពីគោលការណ៍សម្រាប់ការប្រឡងមធ្យមសិក្សាចំណេះទូទៅ ប្រឡងឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេសនិងវិជ្ជាជីវៈ ប្រឡងគ្រូបង្រៀន និងប្រឡងអាហារូបករណ៍ និងបទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២០ .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានឧត្តមសិក្សា ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងក្រឹតការ ប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ប្រធាននាយកដ្ឋានទំនាក់ទំនងវប្បធម៌និងអាហារូបករណ៍ ប្រធាននាយកដ្ឋានបុគ្គលិក នាយកវិទ្យាស្ថានជាតិអប់រំកាយនិងកីឡា និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡាត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២០
- ឯកសារ កាលប្បវត្តិ នា. នីតិកម្ម